៩



# សិទ្ធិទទួលបានការការពារក្តីដោយខ្លួនឯង ឬអ្នកតំណាងតាមផ្លូវច្បាប់

## និយមន័យ

ជនជាប់ចោទនៃបទព្រហ្មទណ្ឌទាំងអស់មានសិទ្ធិការពារក្តីរបស់ខ្លួនដោយផ្ទាល់ ឬការពារក្តីតាមរយៈមេធាវីដែលខ្លួនបានជ្រើសរើស។

សិទ្ធិការការពារក្តីដោយខ្លួនឯងចំពោះបុគ្គល ដែលជាប់ចោទពីបទព្រហ្មទណ្ឌ បានធានាថាមានសិទ្ធិ ដោយសិទ្ធិនេះមានន័យថា ជនជាប់ចោទអាចមានសិទ្ធិក្នុងការបដិសេធជំនួយពីមេធាវីនៅក្នុងបរិបទជាក់លាក់ណាមួយ។

ដើម្បីឱ្យសិទ្ធិការពារក្តីដោយខ្លួនឯង ឬសិទ្ធិអ្នកតំណាងតាមផ្លូវច្បាប់មានប្រសិទ្ធិភាព បុគ្គលដែលត្រូវជាប់ចោទពីបទព្រហ្មទណ្ឌក៏ត្រូវតែទទួលបានដំណឹងអំពីសិទ្ធិនេះឱ្យបានគ្រប់គ្រាន់ជាមុនសិន មុននឹងផ្តល់ឱ្យពួកគេនូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវី។



ជនជាប់ចោទមានសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវី ប្រសិនបើពួកគេមិនចង់ការពារក្តីដោយខ្លួនឯង។



សិទ្ធិនេះអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ចាប់ពីដំណាក់កាលស៊ើបអង្កេតបឋម រហូតដល់ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងឧទ្ធរណ៍។

ជនជាប់ចោទមានសិទ្ធិជ្រើសរើសមេធាវីការពារក្តីតំណាងឱ្យខ្លួនបាន។ ចំណុចនេះពិតជាមានសារសំខាន់ណាស់ដើម្បីធានាបានការទុកចិត្ត និងការជឿជាក់រវាងជនជាប់ចោទ និងមេធាវី និងនាំឱ្យមានការការពារក្តីប្រកបដោយប្រសិទ្ធិភាព។

ប្រសិនបើជនមិនអាចមានលទ្ធភាពជួលមេធាវីបាន ជនជាប់ចោទមានសិទ្ធិស្នើសុំមេធាវីដោយមិនគិតថ្លៃនៅពេលណាដែលផលប្រយោជន៍នៃយុត្តិធម៌ទាមទារ។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានអ្នកតំណាងច្បាប់ គឺត្រូវបានការពារយ៉ាងច្បាស់ក្នុងមាត្រា ១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាន៖ ការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។"



# ច្បាប់ជាតិ




សិទ្ធិមានមេធាវីតំណាង គឺត្រូវបានការពារដោយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា “*ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។*” សិទ្ធិនេះក៏បានចែងក្នុងមាត្រាមួយចំនួនដូចជា មាត្រា ១៤៣ មាត្រា ៣០០ និងមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមាត្រា ៦ និង ៥០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនផងដែរ។

## សារសំខាន់

ទោះបីជាដោយផ្ទាល់ ឬតាមរយៈមេធាវី សិទ្ធិការពារក្តីដោយខ្លួនឯង គឺមានសារសំខាន់ណាស់ក្នុងការធានាការទទួលបាន*ការជំនុំជម្រះដោយយុត្តិធម៌*។ ជនជាប់ចោទ ដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវតែទទួលបានការអនុញ្ញាតឱ្យតទល់នឹងការចោទប្រកាន់ប្រឆាំងនឹងខ្លួន។ សិទ្ធិមានអ្នកតំណាងច្បាប់ គឺជាស្នូលមួយ ដែល*ផ្តល់សិទ្ធិស្មើគ្នារវាងជនជាប់ចោទ* និងអយ្យការ ដែលជាចំណុចសំខាន់នៃការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។





អ្នកតំណាងច្បាប់ ជួយឱ្យជនជាប់ចោទរៀបចំការពារក្តីឱ្យបានល្អ និងមានប្រសិទ្ធិភាពសម្រាប់ការការពារ ជាមួយនឹងការជួយពីអ្នកជំនាញច្បាប់ ឬអ្នកដែលអាចផ្តល់យោបល់ផ្នែកច្បាប់ទាក់ទងនឹងការចោទប្រកាន់ និងដើម្បីការពារផលប្រយោជន៍ជនជាប់ចោទនៅក្នុងតុលាការ ក៏ដូចជាធានាថា ជនជាប់ចោទទាំងអស់ គឺទទួលបានច្បាប់ដូចគ្នា និងច្បាប់នេះមិនមានការរើសអើងនោះទេ។

## ដែនកំណត់



សិទ្ធិមានអ្នកតំណាងតាមផ្លូវច្បាប់អាចត្រូវ*បានលះបង់* ប្រសិនបើជនជាប់ចោទមានបំណងចង់ការពារក្តីដោយខ្លួនឯង ក្នុងករណីការលះបង់សិទ្ធិនេះបានធ្វើឡើងដោយមាន*មធ្យោបាយការពារខ្លួនត្រឹមត្រូវ និងច្បាស់លាស់*។ ជនជាប់ចោទក៏នៅតែមានសិទ្ធិក្នុងការលុបចោលនៃការលះបង់សិទ្ធិនេះផងដែរ នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើខ្លួនផ្លាស់ប្តូរគំនិត។

ទោះបីយ៉ាងណាក៏ដោយ សិទ្ធិការពារក្តីដោយខ្លួនឯង គឺ*មិនមែនជាសិទ្ធិដាច់ខាតនោះទេ*។ ជនជាប់ចោទអាចត្រូវបានចាត់តាំងមេធាវីឱ្យ ដែលខុសនឹងបំណងរបស់ខ្លួន នៅពេលដែល*ផលប្រយោជន៍យុត្តិធម៌តម្រូវ*។ ជារួមមក ការរឹតត្បិតសិទ្ធិទទួលបានការការពារក្តីដោយខ្លួនឯងត្រូវតែ*មានកម្មវត្ថុ និងគោលបំណងច្បាស់លាស់* និង*មិនចាកឆ្ងាយពី*ការរក្សាផលប្រយោជន៍យុត្តិធម៌។





សិទ្ធិនេះ មានសារសំខាន់ណាស់ពីព្រោះជនជាប់ចោទ*អាចជ្រើសរើស*មេធាវី ដែលខ្លួនឯងទុកចិត្ត និងជាតំណាងរបស់ខ្លួន។ ហើយសិទ្ធិនៃ*ការជ្រើសរើសមេធាវីនេះ* ក៏មិនមែនជាសិទ្ធិដាច់ខាតនោះដែរ និង*អាចជាមូលហេតុ និងកម្មវត្ថុនៃការរឹតត្បិតបានទៀតផង* ជាពិសេសប្រសិនបើការប្រើប្រាស់សេវាមេធាវីត្រូវបានផ្តល់ប្រាក់កម្រៃដោយរដ្ឋ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
Sweden Sverige
People Change the World Diakonia

cc BY NC SA